នស/រកត/០៣១៦/៣៤៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងនិងផ្តល់ឋានៈ **ឯកឧត្តម ម៉ុម ចរិយា** ជាប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា២**: តែងតាំងនិងផ្តល់ឋានៈជាសមាជិកនិយ័តករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការៈ

១- ឯកឧត្តម **អូក ដូវ៉ានី**

២- ឯកឧត្តម **អ៊ឹម ឌុត្លា**

៣- ឯកឧត្តម **សរ រតនា**

៤- ឯកឧត្តម **ស៊ា ណារ៉េត** ។

**មាត្រា ៣** : តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **សុខ ឡេង** ជាទីប្រឹក្សាអមប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ៤** : ប្រធាន និងសមាជិក នៃនិយ័តករទូរគមនាគមន៍កម្ពុជា ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវបានតែងតាំងសម្រាប់អាណត្តិដំបូង ។ ប្រធាន និងសមាជិក មានអាណត្តិ ៣ (បី) ឆ្នាំ ។ អាណត្តិនេះ អាចបន្តសាជាថ្មីទៀតបាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរស.១៦០៣.៣៤៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ៣៤៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**